ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
មុនអង្គសេចក្តី
លេខ ៥៥
ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩
សាលដីកា
លេខ ៨៥ "II"
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចិន្តា, ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] យោង ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៨៥ សស.ក្រVII (ធ) ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញដែលមាន ៖

-ជនត្រូវចោទ៖

១-ឈ្មោះ [redacted] ចិន្តា ហៅ មុំ ភេទស្រី អាយុ ៥២ឆ្នាំ(កើតឆ្នាំ១៩៦៨) ជនជាតិខ្មែរ មុខរបរនៅផ្ទះ កំរិតវប្បធម៌ថ្នាក់ទី១ ចាស់ៗ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រះសីហនុ ទីលំនៅមុនពេលឃាត់ខ្លួនក្រុម [redacted] ខេត្តព្រះសីហនុ



Scanned with CamScanner

ប្តីឈ្មោះ [redacted] មានកូន ២នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស)។ ប្រវត្តិផ្តន្ទាទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តព្រះសីហនុចំនួន ២៤ថ្ងៃ ករណីដីធ្លីកាលឆ្នាំ២០០០។ ឃុំខ្លួនតាមដីកាសម្រេចឱ្យឃុំខ្លួនលេខ ៣៩៦២តពង/១៩ ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៩ នៅពន្ធនាគារខេត្តព្រះសីហនុ។ (អ្នកប្តឹងសាទុក្ខ)

២-ឈ្មោះ [redacted] សុភា ហៅ [redacted] ស៊ីន ភេទស្រី អាយុ ៤៥ឆ្នាំ កើតឆ្នាំ១៩៧៥ ជនជាតិខ្មែរ មុខរបរមេផ្ទះ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត ទីលំនៅមុនពេលឃាត់ខ្លួនក្រុម [redacted] ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] មានកូន ៥នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស)។ ប្រវត្តិផ្តន្ទាទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តព្រះសីហនុចំនួន ២៤ថ្ងៃ ករណីដីធ្លីកាលពីឆ្នាំ២០០០។ ឃុំខ្លួនតាមដីកាសម្រេចឱ្យឃុំខ្លួនលេខ ៣៩៦២តពង/១៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ នៅពន្ធនាគារខេត្តព្រះសីហនុ។ (អ្នកប្តឹងសាទុក្ខ)

៣-ឈ្មោះ [redacted] យោង ភេទប្រុស អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រជាការពារភូមិ កម្រិតវប្បធម៌ (មិនចេះអក្សរ) ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត ទីលំនៅមុនពេលឃាត់ខ្លួននៅក្រុម [redacted] ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស)។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន(គ្មាន)។ ឃុំខ្លួនតាមដីកាសម្រេចឱ្យឃុំខ្លួនលេខ ៣៩៦២តពង/១៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ នៅពន្ធនាគារខេត្តព្រះសីហនុ។ (អ្នកប្តឹងសាទុក្ខ)

-មានមេធាវីការពារសិទ្ធិឈ្មោះ [redacted] ចំរើន។

៤-ឈ្មោះ [redacted] លក្ខិណា ហៅ ល័ក្ខ ភេទស្រី អាយុ ៣២ឆ្នាំ កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ មុខរបរអាជីវកម្ម កម្រិតវប្បធម៌ថ្នាក់ទី៨ មានទីកន្លែងកំណើតនៅ [redacted] ព្រះសីហនុ ទីលំនៅមុខពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] មានកូន ១នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ)។ ប្រវត្តិនៃការផ្តន្ទាទោសគ្មាន។ ឃុំខ្លួនតាមដីកាសម្រេចឱ្យឃុំខ្លួនលេខ ៣៩៦២តពង/១៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ នៅពន្ធនាគារខេត្តព្រះសីហនុ។

៥-ឈ្មោះ [redacted] ស៊ីណាត ភេទស្រី អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមេផ្ទះ កម្រិតវប្បធម៌ (មិនបានចូលរៀន) ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] មានកូន ៦នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស)។ ប្រវត្តិផ្តន្ទាទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តព្រះសីហនុចំនួន ២៤ថ្ងៃករណីដីធ្លីកាលពីឆ្នាំ២០០០។ ឃុំខ្លួនតាមដីកាសម្រេចឱ្យឃុំខ្លួនលេខ ៣៩៦២តពង/១៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ នៅពន្ធនាគារខេត្តព្រះសីហនុ។

-ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ប្រព្រឹត្តទៅចំណុចភូមិ ១ សង្កាត់លេខ ៣



Scanned with CamScanner

ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤៩៥, មាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សម្បត្តិ ភេទប្រុស សញ្ជាតិខ្មែរ មានអាសយដ្ឋានផ្ទះ [redacted] ក្រុងភ្នំពេញ រាជធានីភ្នំពេញ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ នៅចំណុចភូមិ ១ សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណី ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ដែលបង្កឡើងដោយជនត្រូវចោទចំនួន ៥រូប រួមមាន ១/. [redacted] សុភា ហៅ [redacted] ស៊ីន ភេទស្រី អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ, ២/.ឈ្មោះ [redacted] ចិន្តា ហៅ មុំ ភេទស្រី អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ, ៣/.ឈ្មោះ [redacted] លក្ខិណា ហៅ ល័ក្ខ ភេទស្រី អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ, ៤/.ឈ្មោះ [redacted] ស៊ីណាត ភេទស្រី អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ, និងទី៥/.ឈ្មោះ [redacted] យោង ភេទប្រុស អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ និងបក្ខពួក បានបង្កើតជា សហគមន៍ចំនួន ២៤គ្រួសារកំពេញចាស់ ដោយមានអ្នកតំណាងចំនួន ៥នាក់ ក្នុងការធ្វើសកម្មភាពប្រមូលផ្តុំគ្នា និងហាមឃាត់គ្រឿងចក្រដែលកំពុងឈូសឆាយលើដីដែលជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស ជនជាតិខ្មែរ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០៣០១-០៦៣០, លេខ ១៨០១០៣០១-០៦៤៣, លេខ ១៨០១០៣០១-០៦២១, លេខ ១៨០១០៣០១-០៦៣១, លេខ ១៨០១០៣០១-០៦៣២ ព្រមទាំងធ្វើសកម្មភាពគំរាមកំហែងទារប្រាក់ពីឈ្មោះ [redacted] សម្បត្តិ ក្នុង០១ម៉ែត្រការ៉េតម្លៃ ២៥០ដុល្លារ បើចង់ធ្វើការឈូសឆាយលើដីនោះ មិនដូច្នេះទេពួកគាត់នឹងបន្តហាមឃាត់ថែមទៀត។ ហើយដើម្បីការទាមទាររបស់ពួកគាត់មានប្រសិទ្ធិភាព ពួកគាត់បានទាក់ទងអ្នកសារព័ត៌មានចំនួន ០២នាក់ ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរចាងហ្វាងកាសែត TN និងឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ ប្រធានក្លឹបអ្នកកាសែតឯករាជ្យ ដោយប្រាប់កាលបរិច្ឆេទច្បាស់លាស់មុនពេលដែលពួកគាត់ធ្វើសកម្មភាពហាមឃាត់ណាមួយ លើទីតាំងដីនោះទៅកាន់អ្នកសារព័ត៌មានទាំងពីរនាក់ឱ្យមកសម្ភាសប្រជាជនទាំង ២៤គ្រួសារ ដែលនៅលើដីរបស់ឈ្មោះ [redacted] សម្បត្តិ ជាច្រើនលើកដោយតាំងជាសំណួរញុះញង់ធ្វើឱ្យមហាជនមានការក្តៅក្រហាយទៅលើម្ចាស់ដី ព្រមទាំងបានធ្វើការចែកផ្សាយព័ត៌មានតាមបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (TN HOT NEWS)។ ហើយកន្លងមកជនត្រូវចោទដែលអះអាងថាជាតំណាង និងសមាជិករបស់សហគមន៍ ២៤គ្រួសារនោះគឺធ្លាប់ធ្វើការទាមទារប្រាក់បានជោគជ័យលើដីចំនួន ១០ឡូត៍រួចហើយ ដោយដីឡូត៍ខ្លះបាន ១៨០ដុល្លារ និងឡូត៍ខ្លះទៀតបាន ២០០ដុល្លារ ទៅ២៥០ដុល្លារ ផងដែរ។

Scanned with CamScanner

-បានឃើញ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៨៩៧ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

-មិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] ចិន្តា ហៅ មុំ ភេទស្រី អាយុ ៥២ឆ្នាំ កើតឆ្នាំ១៩៦៨ ជនជាតិខ្មែរ មុខរបរមេផ្ទះ កម្រិតវប្បធម៌ថ្នាក់ទី១ចាស់ ទីកន្លែងកំណើតនៅ [redacted] ខេត្តព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួន [redacted] ព្រះសីហនុ ប្តីឈ្មោះ [redacted] មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រវត្តិផ្តន្ទាទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តព្រះសីហនុចំនួន ២៤ថ្ងៃ ករណីដីធ្លីកាលពីឆ្នាំ២០០០។ ពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ប្រព្រឹត្តនៅចំណុចភូមិ១ សង្កាត់លេខ ៣ ក្រុង/ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤៩៥, មាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំជាបណ្តោះអាសន្ន។

-បានឃើញ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៨៩៨ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

-មិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] សុភា ហៅ [redacted] ស៊ីន ភេទស្រី អាយុ ៤៥ឆ្នាំ កើតឆ្នាំ១៩៧៥ ជនជាតិខ្មែរ មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត មានទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] មានកូន ០៥ នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រវត្តិផ្តន្ទាទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តព្រះសីហនុចំនួន ២៤ថ្ងៃ ករណីដីធ្លីកាលពីឆ្នាំ២០០០។ ពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ប្រព្រឹត្តនៅចំណុចភូមិ ១ សង្កាត់លេខ ៣ ក្រុង/ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤៩៥, មាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំជាបណ្តោះអាសន្ន។

-បានឃើញ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៨៩៩ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

-មិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] លក្ខិណា ហៅ ល័ក្ខ ភេទស្រី អាយុ ៣២ឆ្នាំ កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ មុខរបរអាជីវករ កម្រិតវប្បធម៌ថ្នាក់ទី៨ ទីកន្លែងកំណើតនៅ [redacted] ក្រុងព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួនភូមិ [redacted] ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ)។ ប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុនគ្មាន។ ពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យ



Scanned with CamScanner

ប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ប្រព្រឹត្តនៅចំណុចភូមិ១ សង្កាត់លេខ ៣ ក្រុង/ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤៩៥, មាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំជាបណ្តោះអាសន្ន។

-បានឃើញ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៩០០ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

-មិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] ស៊ីណាត ភេទស្រី អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមេផ្ទះ កម្រិតវប្បធម៌ (មិនបានចូលរៀន) ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល មានទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ ប្តីឈ្មោះ [redacted] មានកូន ០៦នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រវត្តិផ្តន្ទាទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តព្រះសីហនុចំនួន ២៤ថ្ងៃ ករណីដីធ្លីកាលពីឆ្នាំ២០០០។ ពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ប្រព្រឹត្តនៅចំណុចភូមិ១ សង្កាត់លេខ ៣ ក្រុង/ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤៩៥, មាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំជាបណ្តោះអាសន្ន។

-បានឃើញ ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៩០១ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

-មិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] យោង ភេទប្រុស អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រជាការពារភូមិ កម្រិតវប្បធម៌ (មិនចេះអក្សរ) ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត មានទីលំនៅមុនពេលឃាត់ខ្លួន [redacted] ព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស)។ ប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុនគ្មាន។ ពីបទ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ប្រព្រឹត្តនៅចំណុចភូមិ១ សង្កាត់លេខ ៣ ក្រុង/ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤៩៥, មាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំជាបណ្តោះអាសន្ន។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៥៦ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] ចិន្តា, ឈ្មោះ [redacted] សុភា, ឈ្មោះ [redacted] លក្ខិណា, ឈ្មោះ [redacted] ស៊ីណាត និងឈ្មោះ [redacted] យោង ដែលប្តឹងមិនសុខចិត្តនឹងដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៨៩៧ តព/១៩, ៣៨៩៨ តព/១៩, ៣៨៩៩ តព/១៩, ៣៩០០ តព/១៩, ៣៩០១ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។



Scanned with CamScanner

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៥ សស.ក្រVII (ធ) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ចិន្តា, [redacted] សុភា និងឈ្មោះ [redacted] យោង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] ស៊ីណាត ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

៣-តម្កល់ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៨៩៧ តព/១៩, លេខ ៣៨៩៨ តព/១៩ និងលេខ ៣៩០១ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។

៤-បដិសេធដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៨៩៩ តព/១៩ និងលេខ ៣៩០០ តព/១៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តព្រះសីហនុ ជាអសារបង់។

៥-អនុញ្ញាតឱ្យឈ្មោះ

ក-[redacted] លក្ខិណា ហៅ ល័ក្ខ (មានសាវតាជាតិដូចខាងលើ)

ខ [redacted] ស៊ីណាត (មានសាវតាជាតិដូចខាងលើ) ឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន។

៦-បង្គាប់ឱ្យសមត្ថកិច្ចធ្វើការដោះលែងឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] ស៊ីណាត នេះចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ប្រសិនបើឈ្មោះនេះមិនត្រូវឃុំខ្លួនពីបទល្មើស អ្វីផ្សេងទៀតទេ។

៧-ដាក់ជនត្រូវចោទឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] ស៊ីណាត ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយអនុវត្តនូវកាតព្វកិច្ចមួយចំនួនដូចខាងក្រោម ៖

ក-មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

ខ-ត្រូវបង្ហាញខ្លួនតាមការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

គ-មិនត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

បើមិនអនុវត្តតាមកាតព្វកិច្ចខាងលើនេះទេ ចៅក្រមស៊ើបសួរ អាចចាប់ខ្លួនជនត្រូវចោទទាំងពីរនេះមកឃុំខ្លួនជាថ្មីទៀតបាន។

៨-សាលដីកានេះប្រកាសជាសាធារណៈនាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ចំរើន ជាមេធាវីការពារក្ដីឱ្យជនត្រូវចោទឈ្មោះ [redacted] ចិន្តា, [redacted] យោង និងឈ្មោះ [redacted] សុភា ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៥ សស.ក្រVII (ធ) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ គ្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

Scanned with CamScanner

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា នៅក្នុងរឿងនេះចៅក្រមស៊ើបសួរសាលាដំបូង និងសភាស៊ើបសួរសាលាឧទ្ធរណ៍សម្រេចមិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] ចិន្តា , ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] យោង នៅក្រៅឃុំជាបណ្តោះអាសន្ន ហើយជនត្រូវចោទទាំងបីនាក់បានប្តឹងសាទុក្ខ តំណាងមហាអយ្យការយល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនត្រូវចោទទាំងបីនាក់នោះ គឺត្រឹមត្រូវតាមនីតិវិធីនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហើយការសម្រេចសេចក្តីទាំងចៅក្រមស៊ើបសួរសាលាដំបូង និងសភាស៊ើបសួរសាលាឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ តំណាងមហាអយ្យការ សុំឯកភាព និងសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ និងបដិសេធបណ្តឹងសាទុក្ខរបស់ជនត្រូវចោទដោយផ្ទុយនឹងគតិច្បាប់។

- ជនត្រូវចោទឈ្មោះ [redacted] ចិន្តា បានឆ្លើយថា ខ្លួនប្តឹងសាទុក្ខព្រោះចង់សុំនៅក្រៅឃុំ ។

- ជនត្រូវចោទឈ្មោះ [redacted] សុភា បានឆ្លើយថា ខ្លួនប្តឹងសាទុក្ខព្រោះចង់សុំនៅក្រៅឃុំ ។

- ជនត្រូវចោទឈ្មោះ [redacted] យោង បានឆ្លើយថា ខ្លួនប្តឹងសាទុក្ខព្រោះចង់សុំនៅក្រៅឃុំ ។

- លោកមេធាវី [redacted] ចំរើន បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានពិនិត្យសិក្សាសំណុំរឿង និងសេចក្តីសម្រេច និងពិនិត្យមើលលើសេចក្តីសម្រេចក្នុងសាលដីការបស់សាលាឧទ្ធរណ៍ កន្លងមក ខ្លួនយល់ឃើញថា សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍នូវតែមានលក្ខណៈភ័ន្តច្រលំខ្លះ ដោយសារតែទោះបីជាកូនក្តីខ្លួនមានស្ថានភាព និងលក្ខខណ្ឌគ្រប់គ្រាន់ដែលអាចស្នើសុំអនុញ្ញាតនៅក្រៅឃុំជាបណ្តោះអាសន្នបាន តែសាលាឧទ្ធរណ៍នៅតែមិនអនុញ្ញាត។ នៅក្នុងរឿងនេះ យើងឃើញថាទី១ ដើមហេតុដែលពាក់ព័ន្ធជាមួយនឹងកូនក្តីខ្លួន គឺកើតចេញពីទំនាក់ទំនងនៃសិទ្ធិប្រត្យក្សក្នុងរឿងដីធ្លី។ ទី២ យើងឃើញថា ពួកគាត់ទាំង០៥នាក់ភាគច្រើនជាស្ត្រី ហើយសាលាឧទ្ធរណ៍បានលើកយកលក្ខខណ្ឌពិសេសៗខ្លាំង ទើបបានអនុញ្ញាតឱ្យនៅក្រៅឃុំចំនួន ២នាក់។ នៅក្នុងរឿងក្តីនេះ ខ្លួនយល់ឃើញថា ហេតុផលសម្រាប់ពួកគាត់ទាំងអស់ជាហេតុផលសមស្រប និងត្រឹមត្រូវទៅតាមវិធានច្បាប់ដែលមានចែងក្នុងមាត្រា ២០៥។ ក្នុងនោះឃើញថាពួកគាត់មានទីលំនៅច្បាស់លាស់ មានមូលដ្ឋាននៃការជឿជាក់បានថាទោះបីជានៅក្រៅឃុំក៏ពួកគាត់មិនគេចខ្លួនទៅណាដែរ ព្រោះថាមូលដ្ឋានជីវភាព ទ្រព្យសម្បត្តិដែលជាផ្ទះសំបែង គឺច្បាស់លាស់ណាស់ ហើយអ្វីដែលសំខាន់នោះ គឺពួកគាត់មានកាតព្វកិច្ចក្នុងការតតាំងរឿងដីធ្លីច្រើនផ្សេងទៀតនៅសាលាដំបូង។ អ៊ីចឹងផ្អែកតាមមូលដ្ឋានដែលអាចជឿជាក់បានទាំងអស់នេះ និងកត្តាភេទជាស្ត្រីផងនោះ គឺខ្លួនយល់ឃើញថាគឺនៅតែមានលកខណ្ឌអនុគ្រោះអាចឱ្យពួកគាត់នៅក្រៅឃុំ ដោយមិនមានឧបសគ្គខាងនីតិវិធីមួយណាធ្ងន់ធ្ងរសម្រាប់តុលាការបន្តដាក់ពួកគាត់នៅក្នុងឃុំទៀតនោះទេ។ ជាចុងក្រោយក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យកូនក្តីរបស់ខ្លួនទាំងបីនាក់ ឈ្មោះ [redacted] ចិន្តា, ឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] យោង សុំឱ្យឯកឧត្តមប្រធាន និងក្រុមប្រឹក្សាមេត្តាពិចារណាឱ្យពួកគាត់បាននៅក្រៅឃុំជាបណ្តោះអាសន្ន ចាប់ពីពេលនេះទៅ។

Scanned with CamScanner

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនត្រូវចោទ និងសេចក្តីសន្និដ្ឋានមេធាវីការពារជនត្រូវចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ចំរើន មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ចិន្តា, [redacted] យោង និងឈ្មោះ [redacted] សុភា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលជនត្រូវចោទឈ្មោះ [redacted] ចិន្តា, [redacted] យោង និងឈ្មោះ [redacted] សុភា ក៏ដូចជាមេធាវីការពារក្តីបានអះអាងថា អង្គហេតុទំនាស់ជាវិវាទដីធ្លី និងភាគីខ្លួនជាស្រីភេទ មានទីលំនៅច្បាស់លាស់ ដែលមិនអាចគេចខ្លួន ឬបង្កឧបសគ្គដល់នីតិវិធីតុលាការទេ ហេតុនេះភាគីខ្លួនស្នើសុំនៅក្រៅឃុំនោះ តុលាការកំពូលមិនអាចពិចារណាបានទេ ព្រោះថាជនត្រូវចោទជាច្រើនរូប ត្រូវបានដាក់ស្ថិតក្រោមការត្រួតពិនិត្យពីបទល្មើស ប្រើអំពើហិង្សាលើម្ចាស់កាន់កាប់អចលនវត្ថុដោយសុចរិត, ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងកំហែងយក ដែលជាពហុភាពនៃបទល្មើស ហើយបើជនត្រូវចោទនៅក្រៅឃុំមានហានិភ័យខ្ពស់ដែលធ្វើឱ្យប៉ះពាល់ដល់នីតិវិធីរបស់តុលាការ ដូច្នេះវិធានការឃុំខ្លួនលើជនត្រូវចោទទាំងបីរូប ដើម្បីទុកជូនតុលាការចាត់ការតាមនីតិវិធី គឺមានភាពចាំបាច់ស្របតាមស្មារតីមាត្រា ២០៣, ២០៤ និង ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា សេចក្តីសម្រេចរបស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ មានលក្ខណៈត្រឹមត្រូវហើយ ហេតុនេះស្នើសុំតម្កល់សាលដីកាសភាស៊ើបសួរទុកជាបានការទាំងមូល។ ករណីនេះ តុលាការកំពូល ពិចារណាដូចមានខាងលើនេះ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៥ សស.ក្រVII (ធ) ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ៣០៤ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ចំរើន មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ចិន្តា, [redacted] យោង និងឈ្មោះ [redacted] សុភា។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៥ សស.ក្រVII (ធ) ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាបានការ។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner